SWIS-H
STATEWIDE INFANT SCREENING - HEARING



# ខ្ញុំបានជ្រើសរើសមិនឲ្យទារករបស់ខ្ញុំទទួលការពិនិត្យមើលសោតវិញ្ញាណ។ តើខ្ញុំត្រូវការដឹងពីអ្វីខ្លះ?

ទារករបស់អ្នកនឹងបានទទួលការឆែកពិនិត្យមើលសុខភាព មួយចំនួនជាបន្តបន្ទាប់នៅក្នុងរវាងពេល២-៣សប្តាហ៍ដំបូងបន្ទាប់ពីបានកើតមក។

ការឆែកពិនិត្យមើលមួយក្នុងចំណោមការឆែកពិនិត្យទាំងនេះ គឺដើម្បីរកមើលការបាត់បង់សោតវិញ្ញាណ(ការស្តាប់មិនសូវឮ)។

ការពិនិត្យមើលសោតវិញ្ញាណនឹងបានផ្តល់ជូនយ៉ាងឆាប់ តាមលទ្ធភាពអាចធ្វើទៅបានបន្ទាប់ពីបានកើតមក ហើយអាចធ្វើនៅក្នុងមន្ទីរពេទ្យមុន ឬក្រោយការចាកចេញពីមន្ទីរពេទ្យ ឬធ្វើឡើងនៅតាមទីកន្លែងសហគមន៍ក្នុងតំបន់។

មាតាបិតាអាចជំទាស់ផ្តល់ការយល់ព្រមឲ្យទារករបស់គេទទួលការពិនិត្យមើលសោតវិញ្ញាណ។ ការនេះនឹងត្រូវបានគេធ្វើកំណត់ត្រានៅក្នុងកំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ទារក(សៀវភៅពណ៌ខៀវ)។ គេក៏នឹងស្នើសុំអ្នកឲ្យចុះហត្ថលេខាលើហ្វ៊មមួយផងដែរដែលបញ្ជាក់ថា នៅពេលគេផ្តល់ការពិនិត្យមើលសោតវិញ្ញាណនោះ អ្នកបានប្រកែកមិនព្រមទទួលយក។

ប្រសិនបើអ្នកជ្រើសរើសមិនឲ្យទារករបស់អ្នកទទួលការពិនិត្យមើលសោតវិញ្ញាណ គេនៅតែជម្រាបប្រាប់អ្នកជាដដែល អំពីការពិនិត្យមើលសោតវិញ្ញាណ និងសារៈសំខាន់របស់វា។

## ហេតុអ្វីបានជាគេផ្តល់ការពិនិត្យមើលសោតវិញ្ញាណ?

មានទារកប្រហែល១នាក់ ទៅ២នាក់ ក្នុងចំណោមទារក១០០០នាក់ដែលកើតមកនឹងមានការបាត់បង់សោតវិញ្ញាណដ៏ធ្ងន់ធ្ងរ។

ជាការសំខាន់ដែលអ្នកត្រូវស្វែងយល់ឲ្យបានដឹងយ៉ាងឆាប់តាមលទ្ធភាពអាចធ្វើទៅបាន ថាតើទារករបស់អ្នកស្តាប់ឮល្អយ៉ាងណាដែរ ដើម្បីឲ្យអ្នក ហើយនិងទារករបស់អ្នកអាចទទួលបានឱវាទ និងការផ្គត់ផ្គង់ត្រឹមត្រូវ។

មកទល់នឹង ពេលដែលក្មេងចាប់ផ្តើមចេះនិយាយពាក្យមួយម៉ាត់ដំបូងរបស់គេនោះ គេបានស្តាប់នូវភាសាដែលយើងនិយាយអស់រយៈពេលប្រហែលជាមួយឆ្នាំមកហើយ។

ប្រសិនបើទារកមិនស្តាប់ឮល្អទេក្នុងអំឡុងពេលនេះ ការលូតលាស់ផ្នែកនិយាយស្តី និងភាសារបស់គេអាចត្រូវរងប៉ះពាល់។

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម ឬផ្លាស់ប្តូរគំនិតរបស់អ្នកហើយចង់ឲ្យទារករបស់អ្នកទទួលការពិនិត្យមើលសោតវិញ្ញាណ សូមទាក់ទងជាមួយអ្នកសម្របសម្រួលកម្មវិធី SWIS-H ក្នុងតំបន់របស់អ្នកឲ្យបានឆាប់តាមលទ្ធភាពអាចធ្វើទៅបាន។

## តើខ្ញុំត្រូវការធ្វើអ្វីខ្លះក្នុងកាលទារករបស់ខ្ញុំមានវ័យកាន់តែធំឡើង?

សោតវិញ្ញាណអាចមិននៅដដែលដូចគ្នាតាមកាលកន្លង។ ជាការសំខាន់ដែលត្រូវពិនិត្យមើលការលូតលាស់ផ្នែកនិយាយស្តី និងភាសារបស់ទារកអ្នក ដូចគ្នានឹងការឆ្លើយតបរបស់គេទៅនឹងសូរសម្លេងដែរ។

អ្នកអាចយោងទៅបញ្ជីឆែកមើល នៅក្នុងកំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ទារក (សៀវភៅពណ៌ខៀវ) ឬបញ្ជីឆែកមើលនៅទំព័រម្ខាងទៀតដើម្បីពិនិត្យមើលការលូតលាស់របស់កូនអ្នក។

ប្រសិនបើអ្នកមានកង្វល់អំពីសោតវិញ្ញាណ ឬការលូតលាស់ផ្នែកនិយាយស្តី និងភាសារបស់ទារកអ្នកនៅពេលអនាគត សូមរៀបចំឲ្យមានការធ្វើតេស្តសោតវិញ្ញាណរបស់ទារកអ្នក។ សូមស្នើសុំវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់អ្នកឲ្យគេបញ្ជូនលោកអ្នកទៅកាន់សេវាកម្មសមស្របណាមួយ ដើម្បីទទួលការធ្វើតេស្តសោតវិញ្ញាណរបស់ទារកអ្នក ។

ការធ្វើតេស្តសោតវិញ្ញាណអាចធ្វើបាននៅគ្រប់អាយុ។

### សម្រាប់ព័ត៌មានបន្ថែម សូមបើកចូលវិបសាយខាងក្រោមនេះ៖

http://www.health.nsw.gov.au/kids-families

ការទាក់ទងក្នុងតំបន់ / ព័ត៌មានលំអិតអំពីការណាត់ជួប

សម្រាប់ឱវាទផ្នែកសុខភាព សូមទាក់ទង *healthdirect Australia*
http://www.healthdirect.gov.au/
**1800 022 222**

NSW GOVERNMENT | Health

**Khmer** - I chose not to have my baby's hearing screened. What do I need to know?

SWIS-H
STATEWIDE INFANT
SCREENING - HEARING

# បញ្ជីឆែកមើលសោតវិញ្ញាណ

| | |
|---|---|
| ចាប់ពីកំណើត ទៅ៣ខែ | បញ្ចេញប្រតិកម្មទៅនឹងសូរសម្លេងខ្លាំង |
| | ទៅជាស្ងប់ស្ងៀមជាមួយនឹងសម្លេង ឬសូរកងរំពងដែលធ្លាប់ឮ |
| | ធ្វើសម្លេងថ្ងូរ |
| | ឆ្លើយតបទៅនឹងការនិយាយស្តី ដោយសម្លឹងមើលមុខអ្នកនិយាយ |
| ៣-៦ខែ | បែរភ្នែក ឬក្បាលឆ្ពោះទៅរកសម្លេង |
| | ចាប់ផ្តើមបញ្ចេញសម្លេងដូចការនិយាយស្តី |
| | សើច ហើយធ្វើសម្លេងដើម្បីបង្ហាញប្រាប់អំពីអារម្មណ៍របស់គេ |
| ៦-៩ខែ | និយាយកកែកករ ´ដាដា´ ´ម៉ា-ម៉ា´ ´បាបា´ |
| | ស្រែក /បន្លឺសម្លេងដើម្បីទាក់ទាញអារម្មណ៍ |
| | ជាញឹកញយ នឹងឆ្លើយតបទៅពាក្យ´ កុំ ឬ ទេ´  ហើយស្គាល់ឈ្មោះរបស់ខ្លួន |
| | ឆ្លើយតបទៅនឹងចម្រៀង និងភ្លេង |
| ៩-១២ខែ | ត្រាប់តាមសម្លេងនិយាយស្តីរបស់មនុស្សឯទៀត |
| | យល់ពាក្យសាមញ្ញទាំងឡាយដូចជា ´បាល់´ ´ឆ្កែ´ ´ប៉ា´ |
| | ងាកក្បាលទៅរកសម្លេងស្រាលៗ |
| | និយាយពាក្យដំបូងមួយចំនួន |
| ១២-១៨ខែ | ហាក់បីដូចជាយល់ពាក្យថ្មីៗរៀងរាល់សប្តាហ៍ |
| | ធ្វើតាមពាក្យនិយាយណែនាំសាមញ្ញមួយចំនួនដូចជា ´ទៅយកបាល់ ´ |
| | ចង្អុលទៅមនុស្ស ផ្នែកនៃដងខ្លួន ឬប្រដាប់ក្មេងលេងពេលណាគេសួរ |
| | បន្តរៀននិយាយពាក្យថ្មីៗ ថ្វីដ្បិតតែពាក្យទាំងនោះប្រហែលជាមិនសូវច្បាស់ក្តី |
| ១៨-២៤ខែ | មានប្រមាណជា១០០ -  ២០០ពាក្យដែលគេប្រើជាញឹកញាប់ |
| | ស្តាប់រឿងនិទាន ឬចម្រៀងសាមញ្ញ |
| | បញ្ចូលពាក្យពីរ ឬបីជាឃ្លាខ្លីៗ ឧទាហរណ៍ ´ទឹកច្រើន´ |



កំណត់ចំណាំ:



NSW GOVERNMENT | Health

© NSW Health September 2016   SHPN (NKF)150256